PRUDENTIAL
ព្រូដិនសល ធានារ៉ាប់រងអាយុជីវិត

# ក្រុមហ៊ុនព្រូដិនសលកម្ពុជា

## ការផ្តល់ជូនពិសេសលើការបញ្ចុះតម្លៃសម្រាប់ការបង់បុព្វលាភឆ្នាំទី២ ទុកជាមុន
## ខ និងលក្ខខណ្ឌ

១. នៅក្នុងឯកសារស្តីពីខ និងលក្ខខណ្ឌនេះ ពាក្យថា **"អ្នក"** ឬ **"របស់អ្នក"** សំដៅដល់ម្ចាស់បណ្ណសន្យារ៉ាប់រង។ ពាក្យថា **"យើងខ្ញុំ"** **"របស់យើងខ្ញុំ"** **"ក្រុមហ៊ុនព្រូដិនសលកម្ពុជា"** ឬ **"ក្រុមហ៊ុន"** សំដៅដល់ក្រុមហ៊ុន ព្រូដិនសល (ខេមបូឌា) ឡាយហ្វ៍ អឹស្សួរិនស៍ ម.ក ។

២. **"បុព្វលាភឆ្នាំទី២"** សំដៅដល់បុព្វលាភដែលអ្នកបានបង់ ដើម្បីបន្តបណ្ណសន្យារ៉ាប់រងឲ្យមានសុពលភាពនៅឆ្នាំទី២។ ឧទាហរណ៍ បើអ្នកដាក់ពាក្យស្នើសុំទិញបណ្ណសន្យារ៉ាប់រង និងបង់បុព្វលាភដំបូង នៅថ្ងៃទី១ ខែតុលា ឆ្នាំ២០២៣ នោះបុព្វលាភក្នុងឆ្នាំទី២ នឹងដល់កាលកំណត់បង់នៅថ្ងៃទី១ ខែតុលា ឆ្នាំ២០២៤។

, **"ការបង់បុព្វលាភឆ្នាំទី២ទុកជាមុន"** មានន័យថា អ្នកបង់បុព្វលាភឆ្នាំទី២ នៅក្នុងពេលជាមួយបុព្វលាភឆ្នាំទី១ ឬក្នុងកំឡុងពេល ៧ ថ្ងៃ បន្ទាប់ពីអ្នកបានបង់បុព្វលាភឆ្នាំទី១ រួចរាល់។

៤. **"អតិថិជនថ្មី"** សំដៅដល់អ្នកដែលទិញបណ្ណសន្យារ៉ាប់រងណាមួយ របស់ក្រុមហ៊ុនព្រូដិនសលកម្ពុជាចាប់ពីថ្ងៃទី១ ខែតុលា ឆ្នាំ២០២៣។

៥. ដើម្បីមានសិទ្ធិទទួលបានការបញ្ចុះតម្លៃនេះ អ្នកត្រូវជាអតិថិជនថ្មីដែលជាវផលិតផល PRUអនាគតកូនខ្ញុំ ជាមួយនឹងការបង់បុព្វលាភប្រចាំឆ្នាំ។

៦. បើអ្នកទទួលបានសិទ្ធិលើការបញ្ចុះតម្លៃនេះ អ្នកនឹងទទួលបានការបញ្ចុះតម្លៃចំនួន ៣០% ទៅលើការបង់បុព្វលាភឆ្នាំទី២ទុកជាមុន។ ឧទាហរណ៍ អ្នកទិញបណ្ណសន្យារ៉ាប់រង PRUអនាគតកូនខ្ញុំ ដែលមានបុព្វលាភប្រចាំឆ្នាំ USD ១០០០ នៅថ្ងៃទី១ ខែតុលា ឆ្នាំ២០២៣។ អ្នកនឹងតម្រូវឲ្យបង់ USD ១០០០ សំរាប់បុព្វលាភដំបូង ប៉ុន្តែអ្នកនឹងបង់ត្រឹមតែ USD ៧០០ ប៉ុណ្ណោះ សម្រាប់ការបង់បុព្វលាភឆ្នាំទី២ទុកជាមុន។

៧. អ្នកនឹងតម្រូវឲ្យបង់បុព្វលាភប្រចាំឆ្នាំ USD ១០០០ សំរាប់ឆ្នាំទី៣តទៅមុខជាធម្មតា ដើម្បីបន្តសុពលភាពបណ្ណសន្យារ៉ាប់រងរបស់អ្នក។

៨. បើអ្នកលុបចោលបណ្ណសន្យារ៉ាប់រងក្នុងកំឡុងពេល២១ថ្ងៃ បន្ទាប់ពីកាលបរិច្ឆេទចេញបណ្ណសន្យារ៉ាប់រងបុព្វលាភដំបូង និងបុព្វលាភឆ្នាំទី២ ដែលបានបង់ទុកជាមុន និងទទួលបានការបញ្ចុះតម្លៃនោះ នឹងត្រូវសងត្រឡប់ទៅវិញ បន្ទាប់ពីដកចេញនូវថ្លៃពិនិត្យសុខភាព (ប្រសិនបើមាន)។

៩. អ្នកអាចស្នើសុំបង្វិលត្រឡប់បុព្វលាភឆ្នាំទី២ដែលបានបង់ទុកជាមុន និងទទួលបានការបញ្ចុះតម្លៃនោះត្រឡប់ទៅវិញ ប្រសិនបើឆ្នាំទី២ មិនទាន់មកដល់ ប៉ុន្តែអ្នកនឹងមិនទទួលបានសិទ្ធិក្នុងការបញ្ចុះតម្លៃទៀតនោះទេ។ អ្នកនឹងតម្រូវឲ្យបង់បុព្វលាភឆ្នាំទី២ ក្នុងចំនួនកំណត់ជាធម្មតា ដើម្បីបន្តសុពលភាពបណ្ណសន្យារ៉ាប់រងរបស់អ្នក។

១០. បើអ្នកបោះបង់បណ្ណសន្យារ៉ាប់រងរបស់អ្នកមុនឆ្នាំទី២ នោះ*បុព្វលាភឆ្នាំទី២ដែលបានបង់ទុកជាមុន និងទទួលបានការបញ្ចុះតម្លៃនេះ* នឹងត្រូវបង្វិលសងត្រឡប់ទៅវិញ។ ទឹកប្រាក់នៃការបោះបង់បណ្ណសន្យារ៉ាប់រង (ប្រសិនបើមាន) នឹងត្រូវទូទាត់ទៅតាមខ និងលក្ខខណ្ឌនៃបណ្ណសន្យារ៉ាប់រង។

១១. បើសិនបើមានការទាមទារសំណងនៅឆ្នាំទី១ ហើយឆ្នាំទី២ពុំទាន់មកដល់ នោះបុព្វលាភឆ្នាំទី២ដែលបានបង់ទុកជាមុន និងទទួលបានការបញ្ចុះតម្លៃនេះ នឹងត្រូវបង្វិលសងត្រឡប់ទៅវិញ។ ការទាមទារសំណង នឹងត្រូវបានវាយតម្លៃ និងទូទាត់ទៅតាមខ និងលក្ខខណ្ឌនៃបណ្ណសន្យារ៉ាប់រង។

១២. ការចេញបណ្ណសន្យារ៉ាប់រងរបស់អ្នក នឹងត្រូវឆ្លងកាត់ដំណើរការនៃការចេញបណ្ណសន្យារ៉ាប់រងដូចការអនុវត្តជាធម្មតា។

១៣. ខ និងលក្ខខណ្ឌផ្សេងទៀតនៃបណ្ណសន្យារ៉ាប់រងរបស់ផលិតផលនឹងបន្តអនុវត្តដូចធម្មតា។

១៤. ក្រុមហ៊ុនរក្សាសិទ្ធិក្នុងការបញ្ចប់ការបញ្ចុះតម្លៃនេះ ឬផ្លាស់ប្តូរលក្ខខណ្ឌ និងសិទ្ធិក្នុងការទទួលបានការបញ្ចុះតម្លៃនេះ ឬផ្លាស់ប្តូរភាគរយនៃការបញ្ចុះតម្លៃ ដោយពុំចាំបាច់ជូនដំណឹងជាមុននោះទេ។

PRUDENTIAL
ព្រូដិនសលល ធានារ៉ាប់រងអាយុជីវិត

**Prudential Cambodia**

**Special offer to provide Discount on Year 2 Premium Paid in Advance**

**Terms and Conditions**

1. In this Terms and Conditions document, **"you", "your"** means the Policyowner. **"We"**, **"our"**, **"Prudential Cambodia"**, and **"The Company"** means Prudential (Cambodia) Life Assurance Plc.
2. **"Year 2 Premium"** is the premium that is paid by you for year 2 of the policy to continue the in-force status of the policy. For example, if you first submit the application form and pays the initial premium on 1 October 2023, Year 2 premium is due on 1 October 2024.
3. **"Year 2 Premium Paid in Advance"** means you pay Year 2 Premium at the same time with initial premium or within 7 days from the date you pay initial premium.
4. "**New customers**" shall refer to customers who purchase insurance Policy with Prudential Cambodia starting from 1st October 2023.
5. To be eligible for this discount campaign, you have to be New customers who purchase product PRUអនាគតកូនខ្ញុំ with annual premium frequency.
6. If you are eligible for this discount campaign, you are entitled to have 30% discount on Year 2 Premium Paid in Advance. For example, your PRUអនាគតកូនខ្ញុំ policy has annual premium of $1,000 purchased on 1st October 2023. You are required to pay $1,000 as initial premium but pay only $700 for Year 2 Premium Paid in Advance.
7. You are required to pay annual premium of $1,000 from year 3 onward as normal to continue the in-force status of your Policy.
8. If you cancel your Policy within 21 days from policy issuance date, you initial premium and Year 2 Premium Paid in Advance that is discounted will be refunded, minus medical examination cost (if any).
9. You are allowed to request refund of Year 2 Premium Paid in Advance that is discounted back if Year 2 has not reached. However, you are not entitled to this discount anymore. You are required to pay due year 2 premium in full to continue the in-force status of the Policy.
10. If you surrender your Policy before reaching year 2, Year 2 Premium Paid in Advance that is discounted shall be refunded. Surrender value (if any) shall be payable as per usual practice of policy terms and conditions.
11. If claim happens in year 1 and has not reached year 2, Year 2 Premium Paid in Advance that is discounted shall be refunded. Then the claim shall be assessed and settled as per usual practice of policy terms and conditions.
12. The acceptance of your new Policy is subject to underwriting as usual practice.
13. The rest of product's terms and conditions under Insurance Policy are applicable as usual practice.
14. Without any prior notice, we reserve the rights to stop this discount campaign or change the eligibility or discount percentage of this discount campaign.

PRUDENTIAL (CAMBODIA) LIFE ASSURANCE PLC
KINGDOM OF CAMBODIA